**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ: ៥៧០ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦

## ប្រកាស
## ស្ដីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង រៀបចំនីតិវិធីគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នសដែលប្រកាសឱ្យប្រើ ១៩៩៦ខែមករា ឆ្នាំ ២៤ចុះថ្ងៃទី ១៥/០១៩៦/រកម/ច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង រៀបចំនីតិវិធីគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ជូ វិជិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្តម **ជា ចូវ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- | ឯកឧត្តម **ស ថេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៥- | ឯកឧត្តម **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |
| ៦- | ឯកឧត្តម **សេង សត្ថា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៧- | ឯកឧត្តម **សៅ សុផាព** | នាយកខុទ្ទកាល័យក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ឹម យ៉ាន** | អគ្គស្នងការរងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| ៩- ឯកឧត្តម **ខូច សូទៀត** | ជំនួយការអមក្រសួងបរិស្ថាន | សមាជិក |
| ១០- លោក **អូន ម៉ិនហាក់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |
| ១១- លោក **សៀក សុគីត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |
| ១២- លោក **យូ ពិសី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ១៣- កញ្ញា **គង់ រ័ត្នលំអង** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោកឧត្តមសេនីយ៍ទោ **ឡោ សុខឡេង** | ស្នងការ នៃស្នងការដ្ឋានហិរញ្ញកិច្ច និងភស្តុភារ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៥- លោក **ម៉ាន់ ចន្ទី** | ប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១៦- លោកស្រី **យ៉យ ចំន្ទវុត្ថា** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧- លោក **តូ សុគំណា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ១៨- លោក **ហ៊ត់ ធានី** | អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួង មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ធ្វើការសិក្សា និងរៀបចំនីតិវិធីប្រមូល និងគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដែលត្រូវប្រមូលពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- ធ្វើការសិក្សាឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដោយមានការជួបពិភាក្សាជាមួយសាមីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឱ្យកិច្ចដំណើរការប្រមូល និងគ្រប់គ្រងចំណូលនេះ មានភាពរលូន
- ធ្វើរបាយការណ៍ និងផ្តល់យោបល់អំពីជម្រើសនានាដែលពាក់ព័ន្ធនឹងនីតិវិធីនៃការប្រមូល និងការគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ សម្រេច ឬ ផ្តល់ការណែនាំ។

**ប្រការ៣ .-**

សមាសភាពនៃក្រុមការងារអន្តរក្រសួង ដែលមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ឯកឧត្តមប្រធានក្រុមការងារ។

**ប្រការ៤ .-**

ប្រកាសលេខ ២៩១ សហវ.ចមព ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំនីតិវិធីប្រមូល និងគ្រប់គ្រងចំណូលពីកម្រៃសេវាធ្វើដំណើរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ